01634029



**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Dec-2019, 14:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីប្រកាសអំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍ ដាក់ដោយសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence N. MWACHANDE-MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ:**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន:**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្ដីផ្ដើម

1. សេចក្ដីប្រកាសអំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍ ("សេចក្ដីប្រកាស") ត្រូវបានដាក់ដោយសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី Megan Hirst នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានជូនដំណឹងកាលនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩[1]។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ស្ថានភាពដែលបានរៀបរាប់នៅក្នុងសេចក្ដីប្រកាសមិនបង្កើតបានជាទំនាស់ផលប្រយោជន៍ ឬបង្កើតបានជាហានិភ័យណាមួយនៃទំនាស់ផលប្រយោជន៍ ដែលនឹងប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ នោះទេ។ មិនមានកាលៈទេសៈណាមួយដែលបានរៀបរាប់មកនេះ ធ្វើឲ្យអន្តរាយដល់សច្ចធារណ៍នៃអនាគតិរបស់អង្គជំនុំជម្រះ ដែលថៅក្រមនៅ អ.វ.ត.ក មាននោះទេ។

## II. ច្បាប់ជាធរមាន

2. <u>ទាក់ទងទៅនឹងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖</u> វិធាន ១២*ស្ទួនពីរ* (២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងថា "សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិអំណាច តាមវិធានផ្ទៃក្នុងនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវមានកាតព្វកិច្ចលើកកំពស់យុត្តិធម៌ និងដំណើរការនិតិវិធី ប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព"[2]។

3. ក្នុងឋានៈជាអ្នកច្បាប់ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានភ្ជាប់កាតព្វកិច្ចទៅនឹងក្រមសីលធម៌របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("BAKC")[3] ក៏ដូចជាវិធាននានានៃគណៈមេធាវីរបស់ប្រទេសអង់គ្លេស និងវេលស៍ ផងដែរ។ ក្រមសីលធម៌របស់ BAKC "មានគោលបំណងការពារ និងពង្រឹងឯករាជ្យភាព សេរីភាពនៃវិជ្ជាជីវៈមេធាវី និងធានាសេចក្ដីថ្លៃថ្នូររបស់មេធាវី ទាំងក្នុង និងក្រៅការប្រកបវិជ្ជាជីវៈ ដើម្បីបង្កើនជំនឿទុកចិត្តពីសាធារណជន"

---

[1] ឯកសារ **F53/7** សេចក្ដីប្រកាសអំពីលទ្ធភាពនៃទំនាស់ផលប្រយោជន៍ ដោយ Megan Hirst ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ KH 01631696 ("សេចក្ដីប្រកាស")។

[2] *សូមមើល ផងដែរ* ទោះបីជាមិនអនុវត្តដោយផ្ទាល់ចំពោះសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ក៏បទបញ្ញារដ្ឋបាលរបស់ផ្នែកគាំពារការការពារក្ដីនៃ អ.វ.ត.ក ដែលមានគោលការណ៍សីលធម៌ទូទៅមួយចំនួន។ មាត្រា ៩.១ និង ៩.២ ចែងថា "សហមេធាវីមិនត្រូវចូលរួមក្នុងសកម្មភាពដែលមានវិសមិតភាពជាមួយការបំពេញតួនាទី [របស់ខ្លួន]" និងមានកាតព្វកិច្ចដើម្បី "បំពេញភារកិច្ចដោយប្រុងប្រយ័ត្ន ដើម្បីបញ្ចៀសឲ្យបាននូវជម្លោះផលប្រយោជន៍"។

[3] សំណុំរឿង ០០៤-ឯកសារ **D361/4/1/5.1.1** ក្រមសីលធម៌របស់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២ ("ក្រមសីលធម៌របស់ BAKC")។

ក៏ប៉ុន្តែ ខកខានមិនបានដោះស្រាយស្ថានភាពជាក់លាក់ដែលបានរៀបរាប់នៅក្នុងសេចក្តីប្រកាសនោះ[4]។ ក្រមសីលធម៌វិជ្ជាជីវៈនៃការប្រព្រឹត្តទៅរបស់របស់គណៈមេធាវីប្រទេសអង់គ្លេស និងវេលស៍ នៅក្នុង សៀវភៅណែនាំរបស់ក្រុមប្រឹក្សាបទដ្ឋានគណៈមេធាវីបានចែងនៅក្នុងវិធាន C៨ ថា "អ្នកមិនត្រូវធ្វើអ្វីដែលអាចត្រូវបានសាធារណជនមើលឃើញយ៉ាងសមហេតុផលថា បានធ្វើឲ្យមានការអន្តរាយដល់សេចក្តីទៀងត្រង់ សុច្ចរិតភាព (CD3) និង ឯករាជ្យភាព (CD4) នោះទេ"[5]។

4. <u>ទាក់ទងទៅនឹងចៅក្រម អ.វ.ត.ក៖</u> មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣(៣) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងមាត្រា ១០ ថ្មី នៃច្បាប់ អ.វ.ត.ក កំណត់អំពីតុលាការឯករាជ និងមិនលំអៀង។ សច្ចធារណ៍នៃអនាគតិត្រូវបានភ្ជាប់ទៅនឹងចៅក្រម អ.វ.ត.ក តាមរយៈមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង។ វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងអំពីយន្តការសម្រាប់ការប្តឹងជំទាស់ចៅក្រម អ.វ.ត.ក[6]។ តេស្ត៍ *Furundžija* (អត្ថិភាពនៃភាពលំអៀងជាក់ស្តែង ឬការស្តែងចេញមិនអាចទទួលយកបាននូវភាពលំអៀង)[7] និង

---

[4] ក្រមសីលធម៌របស់ BAKC មាត្រា ១។ *សូមមើល ផងដែរ* មាត្រា៣ "នៅគ្រប់កាលៈទេសៈ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ"។ មាត្រា ២៥ ចែងអំពីទំនាស់ផលប្រយោជន៍ដែលបានកើតឡើងរវាងអតិថិជនរបស់មេធាវី ឬ រវាងមេធាវី និងអតិថិជនរបស់ខ្លួន។

[5] សៀវភៅក្រុមប្រឹក្សាបទដ្ឋានគណៈមេធាវី សំណៅ ៤.៣ ផ្នែកទី២ - ក្រមនៃការប្រព្រឹត្តទៅ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ rC8 ចូលមើលថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ត្រង់ https://www.barstandardsboard.org.uk/the-bsb-handbook.html?part=E3FF76D3-9538-4B97-94C02111664E5709&audience=&q= ។ កត់សម្គាល់ ថា rC21 ស្តីពីស្ថានភាពនានានៃទំនាស់ផលប្រយោជន៍ ក៏ប៉ុន្តែបានលើកឡើងជាសំខាន់ពីការកើតឡើងនៃជម្លោះរវាងអតិថិជន ពីរនាក់ ឬ រវាងអ្នកច្បាប់ និងអតិថិជនរបស់ខ្លួន។

[6] *សូមមើល* ឯកសារ **D163.2** គោលការណ៍ក្រមសីលធម៌តុលាការក្រុងបាងកហ្គាឡូ EN 00316264, 66។ ពួកវាចែងថា ចៅក្រមត្រូវអនុវត្តមុខនាទីតុលាការដោយឯករាជ្យ "មិនស្ថិតក្រោមឥទ្ធិពល ការជម្រុញ សម្ពាធ ការគំរាមកំហែង ឬការជ្រែកជ្រែកពីភាគីពាក់ព័ន្ធខាងក្រៅដោយផ្ទាល់ ឬដោយប្រយោល ដោយសារមូលហេតុណាមួយឡើយ" (គោលការណ៍១.១) ចែងថា "ក្នុងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយសមាជិកម្នាក់ៗនៃអ្នកមានវិជ្ជាជីវៈច្បាប់ ដែលប្រកបការងារទៀងទាត់នៅក្នុងតុលាការ ចៅក្រមត្រូវតែជៀសវាងឲ្យផុតពីស្ថានភាពដែលអាចបង្កឲ្យមានមន្ទិលសង្ស័យ ឬការកើតមានការឃោគយល់ ឬភាពលម្អៀងទៅរកភាគីណាមួយ (គោលការណ៍ ៤.៣)។

[7] ឯកសារ **F53/4.1.13** *រដ្ឋអាជ្ញា ទល់នឹង* *Furundžija*, IT-95-17/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១៨៩ ["ក. ចៅក្រមមិនមានអនាគតិ ប្រសិនបើគេរកឃើញថាភាលំអៀងជាក់ស្តែងកើតមាន។ ខ. មានការស្តែងចេញនូវដែលមិនអាចទទួលយកបាននូវភាពលំអៀង ប្រសិនបើ៖ i) ចៅក្រមគឺជាភាគីទៅនឹងរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិនៅក្នុងលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះនឹងនាំឲ្យមានការជម្រុញឲ្យមានហេតុដែលក្នុងនោះគាត់ជាប់ពាក់ព័ន្ធ រួមជាមួយនឹងភាគីមួយក្នុងចំណោមភាគីទាំងឡាយ។ ស្ថិតក្រោមកាលៈទេសៈទាំងនេះការប្តឹងជំទាស់ចៅក្រមចេញពីរឿងក្តីនេះកើតឡើងជាស្វ័យប្រវត្តិ ឬ ii) កាលៈទេសៈទាំងនេះនឹងបណ្តាល

បទដ្ឋាន "អ្នកសង្កេតការដ៏មានហេតុផល" របស់វា ត្រូវបានអនុម័តិយក និងអនុវត្តនៅ អ.វ.ត.ក[8]។ ជាចុងក្រោយ ក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក ដែលត្រូវបានអនុម័តិដោយចៅក្រម អ.វ.ត.ក ក្នុងឆ្នាំ ២០០៨ ចែងក្នុងមាត្រា២(២) ថា "ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន"[9]។

## III. សារណា

5. កាលៈទេសៈដែលបានរៀបរាប់នៅក្នុងសេចក្តីប្រកាសនេះមិនបានបំពេញបទដ្ឋានដែលត្រូវការ ដើម្បីបង្កើតបានជាទំនាស់ផលប្រយោជន៍ ដែលបង្កើតបានជាហានិភ័យ ឬទស្សនៈអំពីទំនាស់ផលប្រយោជន៍បែបនេះឡើយ។ ការពិតដែលត្រូវបានប្រកាសនឹងមិនប៉ះពាល់តាមរបៀបណាមួយដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នោះទេ។ ហើយការពិតទាំងនេះក៏មិនធ្វើឱ្យថមថយដល់ សីលធម៌របស់សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬឯករាជភាព និងអនាគតិភាពរបស់ចៅក្រមបម្រុង Rapoza នោះទេ។

6. ទំនាក់ទំនងរវាងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមបម្រុង Rapoza មានលក្ខណៈដាច់ឆ្ងាយដោយវេលា និងពុំជាក់លាក់ច្បាស់លាស់ មិនអាចប៉ះពាល់ដល់ទំនុកចិត្តរបស់សាធារណជនចំពោះ អ.វ.ត.ក និងសិទ្ធិអំណាចផ្នែកសីលធម៌ និងអនាគតិភាពនៃ

---

ឱ្យអ្នកអង្កេតការណ៍មានហេតុផលដែលត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ ដឹងពីភាពលម្អៀង"]។ *សូមមើលផងដែរ* ឯកសារ **F53/4.1.30** *Akayesu*, ICTR-96-4-A, សាលដីកា អង្គជំនុំជម្រះតុសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ២០៣។ ឯកសារ **F53/4.1.14** *Galić*, IT-98-29-A, សាលដីកា អង្គជំនុំជម្រះតុសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ៣៩។ ឯកសារ **F53/4.1.37** *Nahimana និងគូកន.*, ICTR-99-52-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ៤៩។

[8] *សូមមើលឧទាហរណ៍* ឯកសារ **C11/29** សេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ដិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងរឿងក្តី នួន ជា អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ២០-២១។ ឯកសារ **E5/3** សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ក្រុមប្រឹក្សាជំនុំជម្រះពិសេស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ១១-១២។ ឯកសារ **F53/5.2.2** សេចក្តីសម្រេចលើសំណើរបស់ អៀង ធិរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរិវឌ្ឍ ដោយសារកង្វះឯករាជភាព អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ១០។ ឯកសារ **E314/12/1** សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងដីតចិត្ត ក្រុមប្រឹក្សាជំនុំជម្រះពិសេស ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ៣៣។

[9] ឯកសារ **F53/4.1.1** ក្រមសីលធម៌ចៅក្រម អ.វ.ត.ក មាត្រា ២(២)។

តុលាការរបស់ខ្លួននោះទេ។ ដូចដែលបានបង្ហាញនៅក្នុងសេចក្តីប្រកាសនេះ ទំនាក់ទំនងបែបនេះរវាងតួអង្គក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺមិនមែនជារឿងចំឡែកនោះទេ។ ដូចដែលបានរៀបរាប់ ទំនាក់ទំនងទាំងនោះបានកើតមានឡើងនៅពេលយូរមុនពេលដែលលោកស្រី Megan Hirst ត្រូវបានតែងតាំងជាសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី (*រយៈពេលគ្មានការសង្ស័យ*) ដែលមានចំនួនតិចតួច និងមិនពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមបែបណាមួយនោះទេ។ ភាពពាក់ព័ន្ធគឺមានតែទៅនឹងការផលិតសៀវភៅស្តីពីច្បាប់ព្រហ្មទណ្ឌជាតិ របស់ប្រទេសទីម័រ។ ជាងនេះទៀត វាមានភាពពាក់ព័ន្ធក្នុងការកត់សម្គាល់ថា ចៅក្រម Rapoza ក្នុងនាមជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) បច្ចុប្បន្ននេះមិនចូលរួមក្នុង ការសម្រេចរបស់តុលាការ ដែលចេញដោយ អ.ជ.ត.ក ឡើយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនរំលោភលើកាតព្វកិច្ច ក្រមសីលធម៌ ឬក្រមសីលធម៌នៃការប្រព្រឹត្តណាមួយដែលគាត់ត្រូវគោរពតាមនៅ អ.វ.ត.ក នោះទេ។ ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ទំនាក់ទំនងទាំងនេះមិននាំឲ្យមានភាពលំអៀងជាក់ស្តែង ឬការស្តែងចេញនូវភាពលំអៀងរបស់ចៅក្រមបម្រុង Rapoza ឡើយ។ ជាងនេះទៀត តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា ទំនាក់ទំនងណាបន្តទៀតរវាងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមបម្រុង Rapoza ដែលទាក់ទងទាំងស្រុងទៅនឹងការផលិតសៀវភៅស្តីពីច្បាប់ព្រហ្មទណ្ឌជាតិរបស់ប្រទេសទីម័រ នឹងមិនមានវិសមិតភាពទៅនឹងមុខនាទីរបស់ពួកគាត់រៀងៗខ្លួននៅ អ.វ.ត.ក នេះឡើយ។

## V. ដំណោះស្រាយដែលស្នើឡើង

7. តាមសំអាងហេតុដូចបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលសប្រកាសថា ទំនាក់ទំនងពីមុនរវាងសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមបម្រុង Rapoza មិនបង្កើតបានជាទំនាស់ផលប្រយោជន៍ ឬបង្កើតបានជាហានិភ័យនៃទំនាស់បែបនេះឡើយ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |